# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៨

ថ្ងៃនេះសហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពរក្នុងករណីសំណុំរឿងរបស់កាំង ហ្គិចអ៊ាវ ហៅឌុច។ ដីកាសន្និដ្ឋានស្ថាពរនេះមានជិត២០០ទំព័រជាភាសាអង់គ្លេសនិងជាង៣៥០ទំព័រជាភាសាខ្មែរទាក់ទងអង្គហេតុនិងទឡ្ហីករណ៍ច្បាប់ដែលជួយដល់សហចៅក្រមស៊ើបអង្កេតក្នុងការធ្វើសេចក្តីព្រាងដីកាដំណោះស្រាយរបស់ខ្លួនដែលនឹងក្លាយជាដីកាបញ្ជូនសំណុំរឿងរបស់ ឌុច ទៅជម្រះនៅមុខអង្គជំនុំជម្រះ។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ដោយស្នើឲ្យបើកកិច្ចស៊ើបសួរទៅលើទីតាំងឧក្រិដ្ឋកម្មចំនួន២៥កន្លែង ព្រមទាំងស្នើឲ្យនាំ និង ឃុំខ្លួនជនសង្ស័យចំនួន៥នាក់ពីបទឧក្រិដ្ឋនានាដូចជាបទមនុស្សឃាត និង បទប្រល័យពូជសាសន៍ជាដើម។ ទីតាំងទួលស្លែងស្ថិតនៅក្នុងទីក្រុងភ្នំពេញ ដែលជាទីតាំងមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ និង ប្រធានមន្ទីរនេះក៏បានដាក់បញ្ចូលក្នុងដីកានោះផងដែរ។ នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៧ ឌុច ត្រូវបានចាប់ខ្លួន និងឃុំខ្លួនតាមរយៈដីការបស់ចៅក្រមស៊ើបអង្កេត ហើយដីកានេះត្រូវបានតម្កល់ទុកជាបានការដោយសេចក្តីសម្រេចលើកដំបូងរបស់អង្គបុរេជំនុំជម្រះ។

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០៧ ចៅក្រមស៊ើបអង្កេតបានបំបែកសំណុំរឿងទាក់ទង ស២១ និង ឌុច ០ចេញពីសំណុំរឿងជនត្រូវចោទ ៤នាក់ផ្សេងទៀត។ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតប្រកាសថាកិច្ចស៊ើបសួរក្នុងសំណុំរឿង ឌុច បានបញ្ចប់ហើយ ដោយបង្វិលសំណុំរឿងនេះនៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៨ មកសហព្រះរាជអាជ្ញាដើម្បីធ្វើដីកាសន្និដ្ឋានស្ថាពរ។ តាមវិធានផ្ទៃក្នុងនៃអ.វ.ត.ក ថ្ងៃកំណត់ចុងក្រោយនៃការដាក់ជូនឯកសារនេះ គឺត្រូវនឹងថ្ងៃទី៧ខែសីហា ឆ្នាំ២០០៨។ ដោយយល់ឃើញថាពេលវេលាមានសារៈសំខាន់ការិយាល័យសហព្រះរាជអាជ្ញាបានប្រមូលផ្តុំធនធានមានកម្រិតរបស់ខ្លួន ដើម្បីដាក់ដីកាសន្និដ្ឋានស្ថាពរស្ទើរតែ៣ សប្តាហ៍មុនពេលកំណត់។

ដោយយោងលើភស្តុតាងចំនួនជិត៩០០ដែលផ្តុំចូលគ្នា និង ដោយស្រង់យកករណីយុត្តិសាស្ត្រផ្នែកច្បាប់ជាតិនិងអន្តរជាតិនោះដីកាសន្និដ្ឋានស្ថាពរនេះបង្ហាញជូននូវការយល់ឃើញដ៏ទូលំទូលាយមួយនូវអ្វីដែលសហព្រះរាជអាជ្ញាចាត់ទុកថាជាភស្តុតាងដែលពាក់ព័ន្ធមាននៅក្នុងសំណុំរឿង។ សហព្រះរាជអាជ្ញាលើកឡើងនូវទឡ្ហីករណ៍ច្បាប់គាំទ្រដល់ការចោទប្រកាន់អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និង បទឧក្រិដ្ឋផ្សេងៗទៀតដូចជាអំពីទារុណកម្ម និង មនុស្សឃាតក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលក្នុងនោះសហព្រះរាជអាជ្ញាដាក់ជូនថា ឌុច គួរតែត្រូវបានបញ្ជូនទៅជំនុំជម្រះ។ អនុលោមតាមច្បាប់ សហចៅក្រមស៊ើបអង្កេតពុំស្ថិតនៅក្រោមអំណាចចាប់បង្ខំនៃដីកាសន្និដ្ឋានស្ថាពរនេះឡើយ។ ដោយពិចារណាដល់ករណីនេះសហព្រះរាជអាជ្ញាគឺជាអ្នកត្រូវបង្ហាញភស្តុតាងឲ្យហួសពីវិមតិសង្ស័យ។ជាការពិតណាស់សំណុំរឿងនេះនឹងត្រូវបញ្ជូនទៅជំនុំជម្រះនៅអង្គជំនុំជម្រះក្នុងនោះសហព្រះរាជអាជ្ញាបានដាក់ជូននូវអ្វីដែលខ្លួនគិតថានឹងជាឯកសារដែលផ្តល់ជាជំនួយ និង ប្រកបដោយភាពជឿជាក់បាន។

ឌុច និង បុគ្គលិកក្រោមបង្គាប់នៅស-២១ បានធ្វើឯកសារយ៉ាងល្អិតល្អន់ទាក់ទងនឹងឧក្រិដ្ឋកម្មរបស់ខ្លួន។ ឯកសារដើមរាប់សែនទំព័របានបន្សល់ទុកនៅពេលដែលខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាចនៅថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩។ ឯកសារដែលមិនទាន់បាត់បង់ត្រូវរក្សាទុកដោយសារៈមន្ទីរទួលស្លែង និង មជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារមួយចំនួននៃឯកសារដើមទាំងនេះបង្កើតបានជាសំណុំរឿងនេះឡើង។ ជាងនេះទៅទៀត ចាប់តាំងពីការចាប់ខ្លួនមក ឌុច បានទទួលយកការសួរយកចម្លើយចំនួន២៧លើកដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ហើយបានចូលរួមក្នុងការស៊ើបអង្កេតដល់កន្លែងកើតហេតុដែលនៅកន្លែងនោះ ឌុច ត្រូវបានដាក់ឲ្យពិភាក្សាតទល់គ្នាជាមួយជនរងគ្រោះ និង អតីតបុគ្គលិកមន្ទីរស-២១។ ឌុច បានផ្តល់ នូវចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួន និង ឆ្លើយសំនួរផ្សេងៗដែលលើកឡើងដោយ សហព្រះរាជអាជ្ញា និង ដើមបណ្តឹងរដ្ឋប្បវេណី។

ជាការសំខាន់ សាក្សីជាង៦៣នាក់ត្រូវបានសម្ភាសន៍ដោយសហចៅក្រមស៊ើបអង្កេតក្នុងនោះរួមមានជនរងគ្រោះដែលរស់រានមានជីវិត អតីតកងការពារ និង សាក្សីដែលពាក់ព័ន្ធ។ អ្នកទាំងនេះបានផ្តល់នូវការរៀបរាប់ដ៏រន្ធត់អំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅមន្ទីរស-២១។

ភស្តុតាងដែលដាក់ជូននៅក្នុងដំណាក់កាលជំនុំជម្រះនឹងក្លាយជាសក្ខីកម្មសាធារណៈ និងអចិន្ត្រៃយ៍ទាក់ទងនឹងភាពឃោរឃៅនៃរបបនោះនិងឧក្រិដ្ឋភាពរបស់អ្នកដែលមានតួនាទីនៅក្នុងស្ថាប័ននោះ។